សុខភាព និងជីវិត
កាន់តែប្រសើរ

# AIA LOANCARE

ការពារឥណទានរបស់គ្រឹះស្ថានលោកអ្នក និងធានាអនាគតដ៏ប្រសើរដល់អតិថិជនលោកអ្នក



ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាព

# ជីវិតគឺពិបាកប៉ាន់ស្មាន។

ប៉ុន្តែអនាគតហិរញ្ញវត្ថុរបស់គ្រឹះស្ថានលោកអ្នក និងអតិថិជនរបស់លោកអ្នក មិនចាំបាច់ជារឿងដែលពិបាកប៉ាន់ស្មានឡើយ។

ក្នុងនាមជាគ្រឹះស្ថានផ្តល់ឥណទាន ការការពារសមតុល្យឥណទានរបស់គ្រឹះស្ថានលោកអ្នកមិនត្រឹមតែជាការអនុវត្តអាជីវកម្មល្អប៉ុណ្ណោះទេវាជាការប្តេជ្ញាចិត្តចំពោះស្ថិរភាពរយៈពេលវែង និងការជឿទុកចិត្តពីអតិថិជន។

**AIA LoanCare** ជួយឲ្យគ្រឹះស្ថានលោកអ្នកមានការរៀបចំរួចជាស្រេច បន្ថយហានិភ័យ និងផ្តល់ការការពារដែលមានអត្ថន័យ នៅពេលដែលវាមានសារៈសំខាន់បំផុត។



## តើ AIA LoanCare ជួយការពារឥណទានរបស់គ្រឹះស្ថានលោកអ្នក និងធានាអនាគតដ៏ប្រសើរដល់អតិថិជនលោកអ្នកដោយរបៀបណា?

**AIALoanCare**បានបង្កើតឡើងដើម្បីការពារអតិថិជនឥណទានរបស់លោកអ្នកពីការលំបាកផ្នែកហិរញ្ញវត្ថុដោយផ្តល់ការធានានូវសំណងលើបំណុលដែលនៅសល់ ក្នុងករណីអកុសលដែលគាត់ទទួលមរណភាព ឬរងគ្រោះពិការភាពជាអចិន្ត្រៃយ៍។ ស្របពេលគ្នា វាអាចធានាបានថា គ្រួសាររបស់ពួកគាត់មិនត្រូវទទួលបន្ទុកនៃបំណុលដែលនៅសល់ ឬក៏ត្រូវបាត់បង់ទ្រព្យសម្បត្តិដែលបានដាក់ធានានោះទេ។ វាពិតជាការផ្តល់សុវត្ថិភាពផ្លូវចិត្តកំឡុងពេលជីវិតជួបប្រទះនឹងស្ថានភាពលំបាកបំផុត។

### គម្រោងនេះផ្តល់ជូននូវលក្ខណៈពិសេសដ៏ទាក់ទាញដូចខាងក្រោម៖

**ការការពារទ្វេភាគី – ម្ចាស់ឥណទាន និងកូនបំណុល**

ជួយរក្សាសមតុល្យឥណទានរបស់គ្រឹះស្ថានលោកអ្នកឲ្យល្អប្រសើរ ខណៈពេលការពារអតិថិជនឥណទានរបស់លោកអ្នក និង/ឬគ្រួសាររបស់ពួកគាត់ពីបំណុលដែលនៅសល់ ក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។

**ជម្រើសការពារមានភាពបត់បែន**

ធានាថាអតិថិជនរបស់លោកអ្នកទទួលបានការធានារ៉ាប់រង ដែលសមស្របនឹងតម្រូវការហិរញ្ញវត្ថុរបស់ពួកគាត់ និងផែនការបង់សងឥណទានរបស់ពួកគាត់ មិនថាវាជាគម្រោងទឹកប្រាក់ធានារ៉ាប់រងថយចុះ ឬថេរ។

**ការការពារបន្ថែមលើគ្រោះថ្នាក់ចៃដន្យ**

ផ្តល់អត្ថប្រយោជន៍បន្ថែម សម្រាប់ការជ្រើសរើសយក កញ្ចប់ Pro ក្នុងករណីមរណភាព ឬពិការភាព បង្ករដោយគ្រោះថ្នាក់ចៃដន្យ ដែលវាជាការគាំទ្រហិរញ្ញវត្ថុដ៏ចាំបាច់មួយ សម្រាប់អតិថិជនរបស់លោកអ្នក កំឡុងពេលជីវិតជួបប្រទះនឹងស្ថានភាពដ៏លំបាកបំផុត។

**កម្រិតការការពារខ្ពស់ជាមួយនឹងការដាក់ពាក្យសាមញ្ញ**

មិនចាំបាច់ពិនិត្យសុខភាព សម្រាប់ការធានារ៉ាប់រងដែលមានទំហំទឹកប្រាក់ធានារ៉ាប់រងរហូតដល់ទៅ **100,000** ដុល្លារអាមេរិក ចំពោះអតិថិជនអាយុ **50** ឬតិចជាងនេះ ដែលធ្វើឱ្យការចុះឈ្មោះកាន់តែងាយស្រួល រហ័ស និងអាចទទួលបានការការពារ។

# សេចក្តីសង្ខេបអត្ថប្រយោជន៍

| អត្ថប្រយោជន៍ | ទឹកប្រាក់ធានារ៉ាប់រងសរុប | |
|---|---|---|
| | **កញ្ចប់មូលដ្ឋាន** | **កញ្ចប់ Pro** |
| (ក) អត្ថប្រយោជន៍លើមរណភាព | **100%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន | **100%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន |
| (ខ) អត្ថប្រយោជន៍លើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ | **100%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន | **100%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន |
| (គ) អត្ថប្រយោជន៍បន្ថែមលើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យ | មិនមាន | **100%** នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន |
| (ឃ) ការចូលរួមរំលែកទុក្ខលើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យគ្រោះថ្នាក់ | មិនមាន | **30%** នៃទឹកប្រាក់ធានារ៉ាប់រងដើមគ្រា |

សម្គាល់៖ អត្ថប្រយោជន៍ខាងលើនេះ ត្រូវអនុលោមតាម ខ លក្ខខណ្ឌ និងករណីមិនធានា ដូចដែលបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង។

## ជម្រើសការពារមានភាពបត់បែនតាមការជ្រើសរើសរបស់លោកអ្នក៖

ប្រភេទនៃការធានារ៉ាប់រងមានពីរ **(2)** ជម្រើស សម្រាប់អតិថិជនរបស់លោកអ្នកក្នុងការជ្រើសរើស ដើម្បីឲ្យស័ក្តិសមជាមួយនឹងតម្រូវការហិរញ្ញវត្ថុ និងផែនការបង់សងរបស់ពួកគេ។

**ទឹកប្រាក់ធានារ៉ាប់រងថយចុះ**

ទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាននឹងថយចុះរាល់ឆ្នាំស្របជាមួយការថយចុះនៃចំនួនប្រាក់បំណុល។

**ទឹកប្រាក់ធានារ៉ាប់រងថេរ**

ទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាននឹងរក្សាថេរដូចទឹកប្រាក់ធានារ៉ាប់រងដើមគ្រា។

## អត្ថប្រយោជន៍ពេលបោះបង់បណ្ណសន្យារ៉ាប់រង៖

យើងខ្ញុំដឹងថាអតិថិជនរបស់លោកអ្នកប្រហែលធ្វើការសងបំណុលរបស់ពួកគេមុនកាលកំណត់ ហើយវាកើតឡើងញឹកញាប់ផងដែរ។ហេតុដូចនេះហើយ យើងខ្ញុំផ្តល់ជូនអត្ថប្រយោជន៍ពេលបោះបង់បណ្ណសន្យារ៉ាប់រង ដើម្បីឲ្យសមស្របជាមួយនឹងតម្រូវការដែលអាចកើតមានឡើងនេះ។

## រយៈពេលនៃការធានារ៉ាប់រងតាមការជ្រើសរើសរបស់លោកអ្នក៖

វាជាធម្មតាកំណត់ទៅតាមរយៈពេលនៃឥណទានរបស់អតិថិជនលោកអ្នក ប៉ុន្តែយើងខ្ញុំផ្តល់ជូនជម្រើសដែលមានភាពបត់បែនតាមការជ្រើសរើស ដែលយ៉ាងតិច **1**ឆ្នាំ រហូតដល់ **30**ឆ្នាំប៉ុន្តែកំណត់ត្រឹមរយៈពេលនៃឥណទាន។

# លក្ខខណ្ឌដែលអាចទទួលយកការធានារ៉ាប់រង

| | |
|---|---|
| ម្ចាស់បណ្ណសន្យារ៉ាប់រង៖ | • គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុនមានអាជ្ញាបណ្ណផ្តល់ឥណទាន (ប្រាក់កម្ចី)<br>• អ្នកតំណាងស្ថាប័ន មានអាយុ **18** ឆ្នាំ យ៉ាងតិច នៅថ្ងៃទទួលយកការធានារ៉ាប់រង |
| សមាជិកអ្នកត្រូវបានធានារ៉ាប់រង៖ | • អតិថិជនដែលមានឥណទាន (ប្រាក់កម្ចី) ជាមួយនឹងម្ចាស់បណ្ណសន្យារ៉ាប់រង<br>• អាយុ **18** រហូតដល់ **65**ឆ្នាំ នៅថ្ងៃដែលទទួលយកការធានារ៉ាប់រង |

# ការទូទាត់បុព្វលាភធានារ៉ាប់រង

| | |
|---|---|
| រយៈពេលទូទាត់៖ | ការទូទាត់បុព្វលាភធានារ៉ាប់រងតែមួយលើកគត់ |
| របៀបទូទាត់៖ | ប្រចាំខែ |
| វិធីសាស្រ្តទូទាត់៖ | មធ្យោបាយទូទាត់ទាំងអស់ដែលកំណត់ដោយក្រុមហ៊ុន |
| រយៈពេលអនុគ្រោះ៖ | **30** (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទូទាត់បុព្វលាភធានារ៉ាប់រង |

# ការបង្ហាញជាឧទាហរណ៍



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយឈ្មោះ**BrightFutureFinance**មានឥណទានច្រើនប្រភេទ។ហើយឥណទានអាជីវកម្មខ្នាតតូចជាផលិតផលសំខាន់ ដែលស្របជាមួយនឹងចក្ខុវិស័យ និងបេសសកកម្មរបស់គ្រឹះស្ថាន ដើម្បីគាំទ្រដល់ការចាប់ផ្តើមអាជីវកម្មថ្មី និងសហគ្រិនវ័យក្មេង។ ដើម្បីរក្សាសមតុល្យឥណទានរបស់គ្រឹះស្ថានឲ្យល្អប្រសើរ ខណៈពេលបង្ហាញពីការប្តេជ្ញាចិត្តរបស់គ្រឹះស្ថានចំពោះសុខុមាលភាពហិរញ្ញវត្ថុរយៈពេលវែងរបស់អតិថិជន **BrightFuture Finance** បញ្ចូលផលិតផលធានារ៉ាប់រង**AIA LoanCare** ជាជម្រើសមួយនៃកញ្ចប់ឥណទានសម្រាប់អតិថិជនរបស់ខ្លួនជ្រើសរើស។

**សាច់រឿងទី 1:** លោករ័ត្ន អាយុ 25ឆ្នាំ ជាម្ចាស់អាជីវកម្មខ្នាតតូច ទទួលយកឥណទានអាជីវកម្មចំនួន **50,000** ដុល្លារអាមេរិក ពី **BrighterFuture Finance** សម្រាប់រយៈពេល 8ឆ្នាំ ជាមួយនឹងអត្រាការប្រាក់ប្រចាំឆ្នាំ 6.5% ហើយជ្រើសរើសទទួលយកការធានារ៉ាប់រង **AIA LoanCare**។ ហើយនេះជាកញ្ចប់នៃការធានារ៉ាប់រងរបស់លោករ័ត្នដែលស្ថិតនៅក្រោមផលិតផលធានារ៉ាប់រង **AIA LoanCare** ។



| | |
|---|---|
| កញ្ចប់នៃការធានារ៉ាប់រង៖ | កញ្ចប់ Pro ជាមួយទឹកប្រាក់ធានារ៉ាប់រងថយចុះ |
| ទឹកប្រាក់ធានារ៉ាប់រងដើមគ្រា៖ | 52,87.70 ដុល្លារអាមេរិក |
| រយៈពេលនៃការធានារ៉ាប់រង៖ | 8 ឆ្នាំ |
| ហិរញ្ញប្បទានបុព្វលាភធានារ៉ាប់រង៖ | ដោយគ្រឹះស្ថាន BrightFuture Finance |
| បុព្វលាភធានារ៉ាប់រង៖ | 2,687.70 ដុល្លារអាមេរិក |

## អត្ថប្រយោជន៍សម្រាប់លោកវ័ត្ត និង/ឬអ្នកទទួលផលរបស់គាត់

| | |
|---|---|
| ស្ថានការណ៍ទី 1៖ | **អាជីវកម្មលោកវ័ត្តមានដំណើរការល្អណាស់ ហើយលោកសំរេចចិត្តទូទាត់ឥណទានអាជីវកម្មរបស់គាត់ផ្តាច់ នៅចុងឆ្នាំទី2**<br>• លោកវ័ត្តទទួលបានសំណងពី អេ អាយ អេ ចំនួន **918.59** ដុល្លារអាមេរិក តម្លៃនៃការបោះបង់ការធានារ៉ាបរងរបស់គាត់មុនកាលកំណត់។ បន្ទាប់ពីនេះ ការធានារ៉ាប់រងរបស់គាត់ត្រូវបានបញ្ចប់។ |
| ស្ថានការណ៍ទី 2៖ | **លោកវ័ត្តជាអកុសលទទួលមរណភាពដោយសារជំងឺ នៅក្នុងឆ្នាំទី3**<br>• Brightfuture Finance ដែលជាអ្នកទទួលផលទី 1 ទទួលបានសំណងពី អេ អាយ អេ ចំនួន **41,956.74** ដុល្លារអាមេរិក សម្រាប់អត្ថប្រយោជន៍លើមរណភាព ដើម្បីទូទាត់បំណុលដែលនៅសល់របស់លោកវ័ត្ត។ បន្ទាប់ពីនេះ ការធានារ៉ាប់រងរបស់គាត់ត្រូវបានបញ្ចប់។ |
| ស្ថានការណ៍ទី 3៖ | **លោកវ័ត្តជាអកុសលទទួលមរណភាពដែលបង្ករដោយគ្រោះថ្នាក់ចៃដន្យ នៅក្នុងឆ្នាំទី3**<br>• Brightfuture Finance ដែលជាអ្នកទទួលផលទី 1 ទទួលបានសំណងពី អេ អាយ អេ ចំនួន **41,956.74** ដុល្លារអាមេរិក សម្រាប់អត្ថប្រយោជន៍លើមរណភាព ដើម្បីទូទាត់បំណុលដែលនៅសល់របស់លោកវ័ត្ត។<br>• សមាជិកគ្រួសាររបស់លោកវ័ត្តដែលជាអ្នកទទួលផលទី 2 ទទួលបានសំណងពី អេ អាយ អេ ចំនួន **41,956.74** ដុល្លារអាមេរិក សម្រាប់អត្ថប្រយោជន៍បន្ថែមលើមរណភាពដោយគ្រោះថ្នាក់ចៃដន្យ និងចំនួន **15,806.31** ដុល្លារអាមេរិក សម្រាប់ការចូលរួមរំលែកទុក្ខលើមរណភាពដោយគ្រោះថ្នាក់ចៃដន្យ។ បន្ទាប់ពីនេះ ការធានារ៉ាប់រងរបស់គាត់ត្រូវបានបញ្ចប់។ |

**សាច់រឿងទី 2: លោកតុង** អាយុ 35ឆ្នាំ ជានាយកផ្នែកក្រាហ្វិចឌីហ្សាញ ហើយជាមេគ្រួសារនៃគ្រួសារតូចមួយដែលមានប្រពន្ធនិងកូនពីរនាក់។ គាត់ក៏មានឥណទានគេហដ្ឋានចំនួន **100,000** ដុល្លារអាមេរិក ជាមួយ **BrighterFuture Finance** សម្រាប់រយៈពេល 20ឆ្នាំ អត្រាការប្រាក់ប្រចាំឆ្នាំ 7.0% ហើយគាត់សំរេចចិត្តទទួលយកការធានារ៉ាប់រង **AIA LoanCare** ដើម្បីធានាថាគ្រួសារគាត់នឹងមិនទទួលបន្ទុកបំណុលដែលមិនទាន់សង ឬបាត់បងទ្រព្យសម្បត្តិដែលបានដាក់ធានា ប្រសិនបើមានហេតុការណ៍អកុសលណាមួយកើតឡើងមកលើរូបគាត់។ ហើយនេះជាកញ្ចប់នៃធានារ៉ាប់រងរបស់លោកតុងដែលស្ថិតនៅក្រោមផលិតផលធានារ៉ាប់រង **AIA LoanCare**។

| | |
|---|---|
| កញ្ចប់នៃការធានារ៉ាប់រង៖ | កញ្ចប់មូលដ្ឋាន ជាមួយទឹកប្រាក់ធានារ៉ាប់រងថេរ |
| ទឹកប្រាក់ធានារ៉ាប់រងដើមគ្រា៖ | 100,000 ដុល្លារអាមេរិក |
| រយៈពេលនៃការធានារ៉ាប់រង៖ | 20 ឆ្នាំ |
| ហិរញ្ញប្បទានបុព្វលាភធានារ៉ាប់រង៖ | ដោយថវិកាផ្ទាល់ខ្លួន |
| បុព្វលាភធានារ៉ាប់រង៖ | 10,955 ដុល្លារអាមេរិក |



## អត្ថប្រយោជន៍សម្រាប់លោកតុង និង/ឬអ្នកទទួលផលរបស់គាត់

| | |
|---|---|
| ស្ថានការណ៍ទី 1៖ | **លោកតុងធ្វើការបានល្អ និងទទួលបានប្រាក់រង្វាន់ច្រើន ហើយលោកសំរេចចិត្តទូទាត់ឥណទានគេហដ្ឋានរបស់គាត់ផ្តាច់ នៅចុងឆ្នាំទី10**<br>• លោកតុងទទួលបានសំណងពី អេ អាយ អេ ចំនួន **5,156.59** ដុល្លារអាមេរិក ដែលជាតម្លៃនៃការបោះបង់ការធានារ៉ាប់រងរបស់គាត់មុនកាលកំណត់។ បន្ទាប់ពីនេះ ការធានារ៉ាប់រងរបស់គាត់ត្រូវបាន |
| ស្ថានការណ៍ទី 2៖ | **លោកតុងជាអកុសលទទួលមរណភាព នៅក្នុងឆ្នាំទី11**<br>• Brightfuture Finance ដែលជាអ្នកទទួលផលទី 1 ទទួលបានសំណងពី អេ អាយ អេ ចំនួន **66,773.67** ដុល្លារអាមេរិក សម្រាប់អត្ថប្រយោជន៍លើមរណភាព ដើម្បីទូទាត់បំណុលដែលនៅសល់របស់លោកតុង។<br>• សមាជិកគ្រួសាររបស់លោកតុងដែលជាអ្នកទទួលផលទី 2 ទទួលបានសំណងពី អេ អាយ អេ ចំនួន **33,226.33** ដុល្លារអាមេរិក ដែលជាទឹកប្រាក់នៅសល់បន្ទាប់ពីការទូទាត់បំណុលរួច។ បន្ទាប់ពីនេះការធានារ៉ាប់រងរបស់គាត់ត្រូវបានបញ្ចប់។ |

# ការទាមទារសំណង

ប្រសិនបើលោកអ្នកចង់ធ្វើការទាមទារសំណង លោកអ្នកត្រូវបំពេញទម្រង់បែបបទទាមទារសំណង និងផ្តល់ភស្តុតាងក្នុងកំឡុងពេល 90 (កៅសិប) ថ្ងៃ ពីការកើតឡើងនៃព្រឹត្តិការណ៍ដែលត្រូវបានធានារ៉ាប់រង។ លោកអ្នកអាចទាញយកទម្រង់បែបបទទាមទារសំណងពីគេហទំព័ររបស់យើង aia.com.kh ឬ ពីទីប្រឹក្សាផែនការជីវិត អេ អាយ អេ។

ភស្តុតាងបញ្ជាក់មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ គឺជាឯកសារចាំបាច់ដែលត្រូវតែដាក់ភ្ជាប់ជាមួយនឹងទម្រង់បែបបទទាមទារសំណងមកកាន់ក្រុមហ៊ុន អេ អាយ អេ ខេមបូឌា។ អ្នកទាមទារសំណងអាចស្នើសុំសំណង ប្រសិនបើករណីដែលត្រូវទាមទារសំណងកើតឡើងកំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

# ទទួលយកសំណើធានារ៉ាប់រងរបស់លោកអ្នកថ្ងៃនេះ

សូមទាក់ទង ទីប្រឹក្សាផែនការជីវិត អេ អាយ អេ ឬសេវាបម្រើអតិថិជន AIA Client Care

ទូរស័ព្ទលេខ : (855) 86 999 242 / (855) 23 999 242,

អ៊ីមែល: KH.Care@aia.com,

គេហទំព័រ : aia.com.kh

តេឡេក្រាម : AIACambodia bot

# ករណីមិនធានា

**1. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើមរណភាព**

ក្រុមហ៊ុននឹងមិនធានាលើ មរណភាព ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ពីករណីណាមួយខាងក្រោមនេះ ជំនួសមកវិញក្រុមហ៊ុននឹងបង់ជូននូវតម្លៃនៃការ បោះបង់បណ្ណសន្យារ៉ាប់រង (ប្រសិនបើមាន) ដោយដកបំណុលដែលមាន ហើយបន្ទាប់ពីនេះបណ្ណសន្យារ៉ាប់រងនឹងត្រូវបានបញ្ចប់៖

i. ការធ្វើអត្តឃាត ការធ្វើឱ្យរបួសខ្លួនឯង ទោះបីស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតី កំឡុងពេល 2 (ពីរ) ឆ្នាំចាប់ពីកាលបរិច្ឆេទនៃសុពលភាពធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬ

ii. ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

iii. វីរុសហ៊ីវ និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ និង/ឬការផ្លាស់ប្តូរ ការវិវឌ្ឍន៍ ឬការប្រែប្រួលនៃមេរោគអេដស៍ និង /ឬជំងឺដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ ឬ

iv. ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន ដូចជា ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។

**2. ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ អត្ថប្រយោជន៍លើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យ និង ការចូលរួមរំលែកទុក្ខលើមរណភាព និងពិការភាពដោយគ្រោះថ្នាក់ចៃដន្យ**

ក្រុមហ៊ុននឹងមិនធានាលើមរណភាពដោយគ្រោះថ្នាក់ចៃដន្យ ឬពិការភាពណា ដែលកើតឡើងដោយផ្ទាល់ ឬ ដោយប្រយោល ទាំងស្រុង ឬ ដោយផ្នែក ពីករណីណាមួយខាងក្រោមនេះ៖

i. ការប្រឈមនឹងគ្រោះថ្នាក់ ឬប៉ុនប៉ងធ្វើបាបខ្លួនឯងដោយចេតនា ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ

ii. ការចូលបម្រើក្នុងជួរកងទ័ពក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្តី ឬក្រោមបញ្ជាក្នុងប្រតិបត្តិការ សង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ ឬ

iii. ការធ្វើដំណើរចេញចូល ការប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនតាមមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីសមាជិកអ្នកត្រូវបានធានារ៉ាប់រង គឺជាអ្នកដំណើរធម្មតា ឬសមាជិកអ្នកបម្រើលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ណាមួយ តាមកាលវិភាគនៃអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ និងតាមគន្លងផ្លូវអាកាសសម្រាប់អ្នកធ្វើដំណើរតាមផ្លូវអាកាស ឬ

iv. ព្រឹត្តិការណ៍ដែលបណ្តាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្តដែលកើតមានមុនកាលបរិច្ឆេទនៃសុពលភាពធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាពរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬ

v. ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយលោកអ្នក ឬដោយលោកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

vi. ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬការបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដូចជា ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។

## ការិយាល័យកណ្ដាល

អគារ ជីអាយអេ ថៅអ័រ ជាន់ទី31 ផ្លូវសុភមង្គល ភូមិ14 សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

## សាខាសៀមរាប

អគារលេខ 29 & 30 ផ្លូវហ្សាលដឺហ្គោល
សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

## សាខាកំពង់ចាម

ភូមិ15 សង្កាត់កំពង់ចាម
ខណ្ឌកំពង់ចាម ក្រុងកំពង់ចាម
ខេត្តកំពង់ចាម

## សាខាបាត់ដំបង

ផ្ទះលេខ2-6 ផ្លូវលេខ3 ភូមិកម្មករ
សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង
ខេត្តបាត់ដំបង

## សាខាកំពត

ផ្លូវលេខ700 ភូមិ1ឧសភា
សង្កាត់កំពង់កណ្ដាល ក្រុងកំពត
ខេត្តកំពត

ហ្វេសប៊ុក

**086 999 242 | AIA.COM.KH | AIA CAMBODIA**